**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ក្រុមហ៊ុន វិនក្រោន (ខេមបូឌា) អ៊ិនដាសស្ទ្រៀល ឯ.ក
## កិច្ចព្រមព្រៀងស្តីអំពីការព្យួរកិច្ចសន្យាការងារ
## រវាង
## ក្រុមហ៊ុន វិនក្រោន (ខេមបូឌា) អ៊ិនដាសស្ទ្រៀល ឯ.ក ជាមួយកម្មករនិយោជិត

ឆ្នាំពីរពាន់ម្ភៃ ខែមេសាថ្ងៃទី ១៦ វេលាម៉ោង០១និង៣០នាទីថ្ងៃត្រង់នៅការិយាល័យក្រុមហ៊ុនវិនក្រោន (ខេមបូឌា) អ៊ិនដាសស្ទ្រៀល ឯ.ក មានកិច្ចប្រជុំពិភាក្សា រវាងតំណាងក្រុមហ៊ុនប្រតិភូបុគ្គលិក និងកម្មករនិយោជិក ថ្នាក់ដឹកនាំសហជីព ទឹកចិត្តកម្មករកម្ពុជា ប្រចាំរោងចក្រ។ ក្រោយពីបានប្រជុំពិភាក្សា ភាគីទាំងពីរបានយល់ព្រមព្រៀងគ្នាដូចខាងក្រោម

១-ភាគីទាំងពីរយល់ព្រមព្យួរការងាររយៈពេលពីរខែ ( គិតជាថ្ងៃ៦០ថ្ងៃ) សំរាប់កម្មករនិយោជិតមួយចំនួន៧២នាក់ មានផ្នែកខ្សែទឹកហូ និងផ្នែកពិនិត្យគុណភាព ហើយនឹងផ្នែកដេរ ដោយគិតចាប់ពីថ្ងៃទី២០ខែកក្កដាឆ្នាំ ២០២០ រហូតដល់ ថ្ងៃទី១៧ខែកញ្ញាឆ្នាំ២០២០ ដោយសារខ្វះការកម្មង់ទិញ ស្បែកជើង ព្រោះប្រទេសទាំងនោះរងផលប៉ះពាល់ពីជម្ងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ ខូវីដ១៩ (COVID19)។

២-ភាគីកម្មករនិយោជិតយល់ព្រមទទួលប្រាក់ឧបត្ថម្ភ ៣០ដុល្លារអាមេរិក ពីភាគីនិយោជក និង ៤០ ដុល្លារអាមេរិចដែលជាប្រាក់ឧបត្ថម្ភពិសេសរបស់រាជរដ្ឋាភិបាលដូច្នេះ សរុបកម្មករនិយោជិតម្នាក់ទទួលបាន៧០ដុល្លារអាមេរិចក្នុង១ខែសំរាប់រយៈពេលព្យួរការងារនេះ។

៣-ក្រុមហ៊ុននិងបើកជូនប្រាក់ឧបត្ថម្ភ៣០ដុល្លារអាមេរិចនេះជូនកម្មករនិយោជិត១ខែម្តង។

៤-បងប្អូនត្រូវត្រលប់ចូលមកធ្វើការវិញនាថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២០ ក្នុងករណីបងប្អូន កម្មករមិនបានចូលធ្វើការតាមការកំណត់នេះទេ ក្រុមហ៊ុននឹងអនុវត្តន៏តាមច្បាប់ស្តីពីការងារនិងបទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន។

កិច្ចព្រមព្រៀងនេះ ចាប់អនុវត្តន៏និងមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ:

ថ្ងៃព្រហស្បតិ៍ ១១រោច ខែអាសាឍ ឆ្នាំ ជូត ទោស័ក២៥៦៤
កំពង់ស្ពឺ ថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ ២០២០
តំណាងក្រុមហ៊ុន

ស្នាមមេដៃតំណាងកម្មករនិយោជិត

១-

២-

៣-

៤-

៥-

៦-

Scanned with CamScanner